# ប្រឈមមុខនឹងអនាគតដោយសេចក្តីជំនឿ

អែលឌើរ រ៉ែសុល អិម ណិលសុន
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សេចក្តីពិត សេចក្តីសញ្ញា និងពិធីបរិសុទ្ធរបស់ទ្រង់ជួយយើងឲ្យយកឈ្នះលើការភ័យខ្លាច ហើយប្រឈមមុខនឹងអនាគតដោយក្តីជំនឿ !*

បងប្អូនប្រុសស្រីជាទីស្រឡាញ់ អរគុណអ្នករាល់គ្នាចំពោះការគាំទ្ររបស់អ្នកទាំងដោយការលើកដៃ ទាំងការបម្រើរបស់អ្នកនៅក្នុងផ្ទះ ក្នុងសាសនាចក្រ និងក្នុងសហគមន៍របស់អ្នក ។យើងរីករាយដោយបាននៅជាមួយនឹងអ្នក ហើយឃើញអ្នកអង្គុយជាមួយគ្រួសារនិងមិត្តភក្តិ ។ មិនថាអ្នករស់នៅទីណាទេ យើងបានសង្កេតឃើញពីការខិតខំរបស់អ្នក ក្នុងការធ្វើឲ្យពិភពលោកនេះក្លាយជាកន្លែងដ៏ប្រសើរមួយ ។ យើងគាំទ្រអ្នក ! យើងស្រឡាញ់អ្នក ! ដូចជាអ្នកបានអធិស្ឋានឲ្យយើង ដូច្នេះយើងនឹងអធិស្ឋានសម្រាប់អ្នកវិញ !

យើងស្រមៃថា គ្រួសារអ្នកបានអង្គុយជុំគ្នានៅពីមុខទូរទស្សន៍ ឬតាមអ៊ីនធឺណិត ដើម្បីមើលការចាក់ផ្សាយសន្និសីទទូទៅនៅឯផ្ទះ ។ មានគ្រួសារមួយបានផ្ញើរូបភាពមួយឲ្យខ្ញុំ ជារូបភាពដែលគេបានថតនៅពេលសន្និសីទ ។គេបានសង្កេតឃើញពីប្រតិកម្មនៃកូនប្រុសរបស់គេដែលពេលនោះមានអាយុ 18 ខែ ពេលគាត់ស្គាល់ពីរូបរាង និងសម្លេងរបស់អ្នកនិយាយ ។ ក្មេងនោះបានផ្តើមបង្ហាញការថើបរបស់ខ្លួននៅមុខកញ្ចក់ទូរទស្សន៍ ។ គាត់ចង់ទៅឲ្យជិត ។ ដូច្នេះបងស្រីគាត់ក៏បានលើកគាត់ឡើងឲ្យជិះលើស្មា ហើយនាំគាត់ទៅមើលឲ្យជិត ។ នេះគឺជារូបថតនោះ ។

ពិតណាស់ រូបនៅលើទូរទស្សន៍នោះគឺជារូបខ្ញុំ ហើយក្មេងទាំងនោះគឺជាចៅយើង ។ នៅប៉ុន្មានឆ្នាំទៀត ក្មេងប្រុសនេះនឹងជាអែលឌើរ ទទួលអំណោយទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ និងរៀបចំខ្លួនជាស្រេចសម្រាប់បេសកកម្ម ។ក្រោយមក គាត់នឹងផ្សារភ្ជាប់នឹងដៃគូដ៏អស់កល្បដែលគាត់រើស ។ តើអ្នកអាចស្រមៃឃើញថាគាត់ក្លាយជាស្វាមីនិងឪពុក ដោយមានកូនផ្ទាល់ខ្លួននៅថ្ងៃមួយដែរឬទេ ?ហើយនៅថ្ងៃមួយគាត់នឹងនិយាយលាដល់ជីតាគាត់ ដោយដឹងយ៉ាងច្បាស់ថា ការស្លាប់គឺជាផ្នែកមួយនៃជីវិត ។
វាជាការពិត ។ យើងរស់ដើម្បីស្លាប់ ហើយយើងស្លាប់ដើម្បីរស់ម្តងទៀត ។ ក្នុងទស្សនវិស័យដ៏អស់កល្ប ការស្លាប់ដែលមិនពេញលេញ គឺជាការស្លាប់នៃអ្នកដែលមិនបានរៀបចំខ្លួនទៅជួបព្រះ ។

ក្នុងនាមជាពួកសាវក និងជាពួកព្យាការី យើងខ្វល់ខ្វាយទាំងកូនចៅរបស់យើង និងកូនចៅរបស់អ្នក ហើយសម្រាប់កូនចៅម្នាក់ៗរបស់ព្រះផងដែរ ។កិច្ចការគ្រប់យ៉ាងដែលនឹងកើតនាអនាគតសម្រាប់កូនចៅដ៏ពិសិដ្ឋម្នាក់ៗនៃព្រះ នឹងត្រូវបានរៀបចំដោយឪពុកម្តាយ គ្រួសារ មិត្តភក្តិ និងគ្រូរបស់គេ ។ ដូច្នេះក្តីជំនឿយើង *នៅពេលនេះ* បានក្លាយជាផ្នែកនៃក្តីជំនឿរបស់កូនចៅយើង*ជំនាន់ក្រោយ* ។

បុគ្គលម្នាក់នឹងធ្វើដំណើររបស់ខ្លួនក្នុងពិភពលោកមួយដែលផ្លាស់ប្តូរជាបន្តបន្ទាប់ ---ជាពិភពលោកមួយដែលមានការប្រកួតខាងមនោគមវិជ្ជា ។ កម្លាំងនៃក្តីអាក្រក់នឹងទាស់ប្រឆាំងនឹងកម្លាំងនៃក្តីល្អជានិច្ច ។ សាតាំងព្យាយាមជាបន្តបន្ទាប់ដើម្បីធ្វើឲ្យយើងដើរតាមផ្លូវវា ហើយធ្វើឲ្យយើងលំបាកដូចជាវាដែរ ។[1] ហើយវិបត្តិធម្មតាក្នុងជីវិតដូចជា ជំងឺ របួស និងគ្រោះថ្នាក់នឹងកើតឡើងជានិច្ច ។

យើងរស់នៅក្នុងគ្រាចលាចល ។ ការរញ្ជួយដី និងព្យុះរលក ស៊ូណាមិ បង្កឲ្យមានភាពហិនហោច ធ្វើឲ្យរដ្ឋាភិបាលធ្លាក់ចុះ ជួបវិបត្តិសេដ្ឋកិច្ចធ្ងន់ គំរាមកំហែងដល់គ្រួសារ ហើយអត្រានៃការលែងលះកំពុងតែកើនឡើង ។ យើងមានបុព្វហេតុដ៏ធំដែលខ្វល់ខ្វាយ ។ តែយើងមិនត្រូវបណ្តោយឲ្យការភ័យខ្លាចយើងយកឈ្នះលើក្តីជំនឿយើងឡើយ ។ យើងអាចទ្រាំទ្រនឹងការភ័យខ្លាចទាំងនោះដោយការពង្រឹងក្តីជំនឿយើង ។

សូមផ្តើមជាមួយនឹងកូនអ្នក ។ ឪពុកម្តាយទាំងឡាយ អ្នកមានទំនួលខុសត្រូវដ៏សំខាន់ដើម្បីពង្រឹងដល់ក្តីជំនឿគេ ។ ចូរឲ្យពួកគេឃើញពីក្តីជំនឿអ្នក ទោះជាមានការសាកល្បងដ៏ធំកើតឡើងចំពោះអ្នកក្តី ។ ចូរឲ្យក្តីជំនឿអ្នកត្រូវបានផ្តោតលើព្រះវរបិតាសួគ៌យើង និងព្រះរាជបុត្រារបស់ទ្រង់ ព្រះ -អម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ សូមបង្រៀនពួកគេឲ្យមានក្តីជំនឿដ៏ជ្រាលជ្រៅ ។ សូមបង្រៀនដល់ក្មេងប្រុសស្រីម្នាក់ៗថា គេជាបុត្រនៃព្រះ ដែលបានបង្កើតតាមរូបភាពទ្រង់ ហើយមានគោលបំណងនិងសក្តានុពលដ៏ពិសិដ្ឋ ។[2]

សូមបង្រៀនពីក្តីជំនឿលើផែនការសង្គ្រោះរបស់ព្រះ ។ សូមបង្រៀនថា ដំណើរក្នុងជីវិតរមែងស្លាប់គឺជាពេលសាកល្បង ជាពេលដកពិសោធន៍ដើម្បីឃើញថា យើងនឹងធ្វើនូវអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យយើងធ្វើ ។[3]

សូមបង្រៀនពីក្តីជំនឿ ដើម្បីរក្សា*រាល់* បទបញ្ញត្តិនៃព្រះដោយដឹងថាវាបានប្រទានឲ្យដើម្បីផ្តល់ពរជ័យដល់កូនចៅទ្រង់ និងធ្វើឲ្យគេមានអំណរ ។[4] សូមបម្រាមគេថា គេនឹងជួបមនុស្សដែលនឹងរើសនូវបទបញ្ញត្តិដែលគេចង់គោរព ហើយរំលងនូវបទបញ្ញត្តិផ្សេងទៀតដែលគេមិនចង់គោរព ។ ខ្ញុំសូមហៅការណ៍នេះថាជាការជ្រើសរើសបទបញ្ញត្តិដែលចង់គោរព ។ ការអនុវត្តន៍នៃការជ្រើសរើសនេះនឹងមិនដំណើរឡើយ ។ វានឹងនាំទៅរកភាពទុក្ខសោក ។ ដើម្បីរៀបចំជួបនឹងព្រះ បុគ្គលម្នាក់ត្រូវតែគោរព*រាល់*បទបញ្ញត្តិទ្រង់ ។ វាត្រូវការក្តីជំនឿដើម្បីគោរពតាម ហើយការគោរពបទបញ្ញត្តិទ្រង់នឹងពង្រឹងដល់ក្តីជំនឿនោះ ។

ការគោរពអនុញ្ញាតឲ្យពរជ័យរបស់ព្រះហូរមកដោយឯកឯង ។ ទ្រង់នឹងប្រទានពរដល់កូនចៅទ្រង់ដែលមានការគោរពឲ្យរួចផុតពីសេរកភាព និងទុក្ខសោក ។ ហើយទ្រង់ប្រទានពរនូវពន្លឺថែមទៀតដល់គេ ។

ឧទាហរណ៍ បុគ្គលម្នាក់ដែលគោរពតាមពាក្យសម្តីនៃប្រាជ្ញាវាងវៃ ដឹងថាការគោរពនោះនឹងជួយឲ្យរួចផុតពីការញៀន ព្រមទាំងបន្ថែមនូវពរជ័យនៃប្រាជ្ញា និងទ្រព្យនៃចំណេះវិជ្ជាផងដែរ ។[5]សូមបង្រៀនពីក្តីជំនឿ ដើម្បីដឹងថា ការគោរពតាមបទបញ្ញត្តិព្រះនឹងផ្តល់នូវការការពារខាងរូបកាយ និងខាងវិញ្ញាណ ។ ហើយសូមចាំថា ពួកទេវតាដ៏បរិសុទ្ធនៃព្រះនឹងចាំជួយយើងជានិច្ច ។ព្រះអម្ចាស់បានប្រកាសថា ៖ « យើងនឹងនៅខាងស្តាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង » ។[6] នេះជាការសន្យាដ៏អស្ចារ្យ ! ពេលយើងស្មោះត្រង់ នោះទ្រង់និងពួកទេវតាទ្រង់នឹងជួយយើង ។

ក្តីជំនឿដ៏រឹងមាំត្រូវបានពង្រឹងដោយការអធិស្ឋាន ។ ការទូលអង្វរដ៏អស់ពីចិត្តអ្នកគឺជារឿងដ៏សំខាន់ចំពោះទ្រង់ ។ សូមគិតពីការអធិស្ឋានដ៏អស់ពីចិត្តរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នៅគ្រាដ៏គួរឲ្យភ័យខ្លាចរបស់លោកនៃការជាប់ឃុំឃាំងក្នុងគុកលីប៊ើធី ។ព្រះអម្ចាស់បានឆ្លើយតបដោយផ្លាស់ប្តូរនូវទស្សនវិស័យរបស់ព្យាការី ។ ទ្រង់មានបន្ទូលថា « បុត្រយើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះនឹងផ្តល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ » ។[7]

បើយើងអធិស្ឋានដោយមានទស្សនវិស័យដ៏អស់កល្ប នោះយើងមិនចាំបាច់ឆ្ងល់ថាតើការទូលអង្វរដ៏សោកសៅនិងអស់ពីចិត្តយើងនឹងស្តាប់ឮឬអត់នោះទេ ។ការសន្យានេះមកពីព្រះអម្ចាស់ត្រូវបានកត់ត្រាក្នុងកណ្ឌទី 98 ក្នុងគោលលទ្ធិនិងសេចក្តីសញ្ញាថា ៖ « ការអធិស្ឋានរបស់អ្នកបានចូលក្នុងព្រះកាណ៌របស់ព្រះអម្ចាស់ ... ហើយត្រូវបានកត់ទុកដោយតម្រានិងទីបន្ទាល់នេះ ---គឺព្រះអម្ចាស់ទ្រង់បានស្បថ ហើយបានចេញបញ្ញត្តិថា ពួកគេនឹងត្រូវបានអនុញ្ញាតហើយ ។

« ហេតុដូច្នេះហើយ ព្រះអង្គប្រទានសេចក្តីសន្យានេះដល់អ្នក ដោយសេចក្តីសញ្ញាដ៏មិនចេះប្រែប្រួលថា ការអធិស្ឋានទាំងឡាយនឹងត្រូវបានសម្រេច ហើយគ្រប់ការណ៍ទាំងអស់ដែលអ្នកត្រូវបានរងទុក្ខ នោះនឹងផ្សំគ្នាសម្រាប់សេចក្តីល្អដល់អ្នក និងដល់សិរីល្អរបស់ព្រះនាម យើងព្រះអម្ចាស់ ទ្រង់មានបន្ទូលថាដូច្នោះ » ។[8]

ព្រះអម្ចាស់បានជ្រើសរើសបន្ទូលដ៏ម៉ឺងម៉ាត់បំផុតរបស់ទ្រង់ដើម្បីអះអាងដល់យើង ! *តម្រា ! ទីបន្ទាល់ ! បានស្បថ ! បានចេញបញ្ញត្តិ ! សេចក្តីសញ្ញាមិនចេះប្រែប្រួល !* បងប្អូនប្រុសស្រីទាំងឡាយ សូមជឿទ្រង់ ! ព្រះនឹងស្តាប់នូវការអធិស្ឋានដ៏ស្មោះត្រង់និងអស់ពីចិត្តរបស់អ្នក ហើយក្តីជំនឿអ្នកនឹងបានពង្រឹង ។

ដើម្បីអភិវឌ្ឍក្តីជំនឿដ៏រឹងមាំ នោះការតាំងចិត្តដ៏ម៉ឺងម៉ាត់មួយក្នុងការក្លាយជាអ្នកបង់ដង្វាយភាគដប់ពេញលេញគឺជាកត្តាដ៏សំខាន់ ។ ដំបូងឡើយវាត្រូវការក្តីជំនឿក្នុងការបង់ដង្វាយមួយភាគដប់ ។ រួចហើយ អ្នកបង់ដង្វាយមួយភាគដប់អភិវឌ្ឍក្តីជំនឿដ៏ច្រើនរហូតដល់ដង្វាយមួយភាគដប់ក្លាយជាឱកាសមួយដ៏មានតម្លៃ ។ដង្វាយមួយភាគដប់គឺជាក្រឹត្យវិន័យបុរាណមកពីព្រះ ។[9] ទ្រង់បានធ្វើការសន្យាមួយទៅកូនចៅទ្រង់ថា ទ្រង់នឹង « បើកទ្វារស្ថានសួគ៌ ដើម្បីចាក់ព្រះពរ ... ដែលនឹងគ្មានកន្លែងល្មមទុកបានទេ » ។[10]ជាងនេះទៀត ដង្វាយមួយភាគដប់នឹងរក្សាឈ្មោះអ្នកក្នុងចំណោមរាស្ត្រនៃព្រះ ហើយការពារអ្នកក្នុង « ថ្ងៃនៃការសងសឹកនិងការឆេះឆួល » ។[11]

ហេតុអ្វីយើងត្រូវការក្ដីជំនឿរឹងមាំបែបនេះ ? ពីព្រោះរឿងដ៏លំបាកនឹងកើតមាននាអនាគត ។ នៅអនាគតការធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ម្នាក់គឺមិនងាយស្រួលឡើយ ។យើងម្នាក់ៗនឹងទទួលការសាកល្បង ។ សាវកប៉ុលបានព្រមានថា នៅថ្ងៃចុងក្រោយ អ្នកដែលដើរតាមព្រះអម្ចាស់ដោយឧស្សាហ៍« នឹងត្រូវមានសេចក្ដីបៀតបៀនដែរ » ។[12]ការបៀតបៀននោះអាចធ្វើឲ្យអ្នកចុះខ្សោយដោយមិនដឹងខ្លួន ឬលើកទឹកចិត្តឲ្យធ្វើជាគំរូល្អ ហើយក្លាហានក្នុងជីវិតប្រចាំថ្ងៃអ្នក ។

*របៀប*ដែលអ្នកប្រឈមមុខនឹងការសាកល្បងក្នុងជីវិតគឺជាអភិវឌ្ឍនភាពនៃក្ដីជំនឿអ្នក ។ ភាពរឹងមាំកើតឡើងពេលអ្នកចាំថា អ្នកមាននិស្ស័យមួយពីព្រះជាមរតកមួយដ៏មានតម្លៃបំផុត ។ព្រះអម្ចាស់បានរំឭកអ្នកនិងកូនចៅអ្នកថា អ្នកគឺជាកូនចៅនៃព្រះ ថាអ្នកត្រូវបានរក្សាទុកនៅលើស្ថានសួគ៌សម្រាប់ពេលវេលា និងទីកន្លែងជាក់លាក់ដែលអ្នកត្រូវកើត ត្រូវរីកចម្រើន ហើយក្លាយជាអ្នកតំណាងនិងជារាស្ត្រនៃសេចក្ដីសញ្ញារបស់ទ្រង់ ។ពេលអ្នកដើរលើផ្លូវនៃក្ដីសុចរិតរបស់ព្រះអម្ចាស់ នោះអ្នកនឹងទទួលបានពរដើម្បីបន្តក្នុងក្ដីល្អរបស់ទ្រង់ ហើយក្លាយជាពន្លឺនិងជាព្រះអង្គសង្គ្រោះរបស់រាស្ត្រទ្រង់ ។[13]

បងប្អូនប្រុសស្រីទាំងឡាយ ឱកាសរបស់អ្នករាល់គ្នាគឺជាពរជ័យដែលទទួលបានតាមរយៈអំណាចនៃបព្វជិតភាពមិលគីស្សាដែកដ៏បរិសុទ្ធ ។ពរជ័យទាំងនេះបានផ្លាស់ប្ដូរស្ថានភាពនៃជីវិតអ្នក ដូចជាសុខភាព ភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ទំនាក់ទំនងផ្ទាល់ខ្លួន និងឱកាសសម្រាប់អនាគត ។ អំណាចនិងសិទ្ធិអំណាចនៃបព្វជិតភាពមាននូវកូនសោសម្រាប់រាល់ពរជ័យក្នុងសាសនាចក្រនេះ ។[14] ហើយដែលសំខាន់បំផុតនោះ គឺព្រះអម្ចាស់បានប្រកាសថាទ្រង់នឹងគាំទ្រដល់ពរជ័យទាំងនោះ ស្របតាមព្រះឆន្ទៈទ្រង់ ។[15]

រាល់ពរជ័យបព្វជិតភាពដ៏មហិមាជាងគេបំផុតត្រូវបានប្រទានឲ្យនៅក្នុងព្រះវិហារបរិសុទ្ធនៃព្រះអម្ចាស់ ។ ការស្មោះត្រង់នឹងសេចក្ដីសញ្ញាដែលបានធ្វើនៅទីនោះនឹងធ្វើឲ្យអ្នកនិងគ្រួសារមានភាពសក្ដិសមសម្រាប់ពរជ័យនៃជីវិតអស់កល្បជានិច្ច ។[16]

រង្វាន់របស់អ្នកមិនមែនកើតឡើងតែក្នុងជីវិតក្រោយនោះទេ ។ មានពរជ័យជាច្រើននឹងក្លាយជារបស់អ្នកនៅក្នុងជីវិតនេះ ក្នុងចំណោមកូនចៅរបស់អ្នក ។ អ្នកដែលជាពួកបរិសុទ្ធដ៏ស្មោះត្រង់មិនបានតតាំងនឹងចម្បាំងក្នុងជីវិតនេះតែម្នាក់ឯងឡើយ ។សូមគិតពីការណ៍នោះ ! ព្រះអម្ចាស់បានប្រកាសថា « យើងតតាំងចំពោះអ្នកដែលតតាំងនឹងអ្នក ហើយយើងនឹងជួយសង្គ្រោះកូនចៅអ្នកដែរ » ។[17] ក្រោយមកការសន្យានេះចំពោះរាស្ត្រដ៏ស្មោះត្រង់របស់ទ្រង់បានកើតឡើង ៖ « យើងជាព្រះអម្ចាស់នឹងច្បាំងចម្បាំងរបស់ពួកគេនិងរបស់កូនចៅរបស់ពួកគេ និងរបស់កូនចៅរបស់ពួកគេដែរ...លុះដល់តំណទីបីទីបួន ។[18]

ប្រធាន ថូម៉ាស អេស ម៉នសុន ជាទីស្រឡាញ់របស់យើង បានផ្ដល់ឲ្យនូវសាក្សីនៃការព្យាករណ៍របស់លោក ។ លោកមានប្រសាសន៍ថា « ខ្ញុំសូមថ្លែងទីបន្ទាល់ដល់អ្នកថា ពរជ័យរបស់យើងដែលបានសន្យាគឺមានភាពលើសលប់ណាស់ ។ តាមរយៈការសាកល្បងនិងការលំបាកដែលអាចកើតមានចំពោះយើង នោះចំណេះដឹងរបស់យើងពីដំណឹងល្អនិងក្ដីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះយើងនឹងលួងលោម ហើយគាំទ្រយើង ហើយនាំក្ដីអំណរមកកាន់ដួងចិត្តយើង ពេលយើងរស់នៅដោយសុចរិតហើយគោរពតាមបទបញ្ញត្តិ » ។

ប្រធាន ម៉នសុន បានបន្តទៀតថា « បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ចូរកុំខ្លាចឡើយ ។ ចូរអរសប្បាយចុះ ។ អនាគតគឺភ្លឺថ្លាដូចជាក្ដីជំនឿរបស់អ្នកដែរ » ។[19] (បញ្ចប់ការដកស្រង់ )

ខ្ញុំសូមបន្ថែមទៅលើការប្រកាសដ៏មានខ្លឹមសាររបស់ប្រធាន ម៉នសុន ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះជាព្រះវរបិតាយើង ។ ព្រះយេស៊ូវជាព្រះគ្រីស្ទ ។ សាសនាចក្រទ្រង់បានស្ដារឡើងវិញនៅលើផែនដីនេះ ។ សេចក្ដីពិត សេចក្ដីសញ្ញា និងពិធីបរិសុទ្ធរបស់ទ្រង់ជួយយើងឲ្យយកឈ្នះលើការភ័យខ្លាច ហើយប្រឈមមុខនឹងអនាគតដោយក្ដីជំនឿ ! ខ្ញុំសូមថ្លែងទីបន្ទាល់ដូច្នេះក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល នីហ្វៃទី 2 2:27។
2. ពេត្រុសបានបង្រៀនពីទស្សនៈនោះពេលគាត់សម្ដែងនូវក្ដីសង្ឃឹមថា « អ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ ដោយសារសេចក្ដីសន្យានេះឯងដោយបានរួចពីសេចក្ដីពុករលួយនៅក្នុងលោកិយនេះ ដែលកើតអំពីសេចក្ដីប៉ងប្រាថ្នា » ( ពេត្រុសទី 2 1:4 ) ។
3. សូមមើល អ័ប្រាហាំ 3:25 ។

4. សូមមើល នីហ្វៃទី 2 2:25 ។

5. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 89:19 អេសាយ 45:3 ។

6. គោលលទ្ធិ និងសេចក្ដីសញ្ញា 84:88 ។

7. គោលលទ្ធិ និងសេចក្ដីសញ្ញា122:7 ។ គំរូមួយទៀតនៃការផ្លាស់ប្ដូរនៃទស្សនវិស័យត្រូវបានកត់ត្រាក្នុងទំនុកដំកើងថា « សូមការពារព្រលឹងទូលបង្គំ ...ឱព្រះអម្ចាស់អើយ សូមអាណិតមេត្តាដល់ទូលបង្គំផង ត្បិតទូលបង្គំអំពាវនាវដល់ទ្រង់ជាដរាបរាល់ថ្ងៃ ... ។ ឱព្រះអម្ចាស់ ជាព្រះនៃទូលបង្គំអើយ ទូលបង្គំនឹងសរសើរទ្រង់ឲ្យអស់ពីចិត្ត ។

8. គោលលទ្ធិ និងសេចក្ដីសញ្ញា 98:2–3

9. ដង្វាយមួយភាគដប់ត្រូវបានលើកឡើងក្នុងព្រះគម្ពីរចំនួនប្រាំបីក្នុងព្រះគម្ពីរសញ្ញាចាស់គឺ ៖ លោកុប្បត្តិ, លេវីវិន័យ, ជនគណនា ចោទិយកថា របាក្សត្រទី 2, នេហេមា, អេម៉ុស និងម៉ាឡាគី ។

10. ម៉ាឡាគី 3:10 ។

11. គោលលទ្ធិ និងសេចក្ដីសញ្ញា 85:3 ។

12. ធីម៉ូថេទី 2 3:12 ។

13. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 86:811 ។

14. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 107:18 ។

15. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 132:47, 59 ។

16. សូមមើល អ័ប្រាហាំ 2:11 ។

17. អេសាយ 49:25 សូមមើលផងដែរ គោលលទ្ធិ និងសេចក្ដីសញ្ញា 105:14 ។

18. គោលលទ្ធិ និងសេចក្ដីសញ្ញា 98:37 ។

19. Thomas S. Monson « Be of Good Cheer » Ensign ខែ ឧសភា ឆ្នាំ 2009 ទំព័រ 92 ។